សម្លេងខ្មែរនៅបរទេស

# ទស្សនៈ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## វត្តខ្មែរកាណាដា
## អំពីវិស័យសិល្បៈក៏ជាយានសំរាប់ណែនាំឲ្យមនុស្សមានសីលធម៌ដែរ

**Website: www.hoksavann.org**

ថ្ងៃទី៣ តុលា ២០០៤

មធ្យោបាយអប់រំមនុស្សឲ្យមានសីលធម៌ មានវិធីជាច្រើនយ៉ាង ក្នុងវិធីទាំងនោះ វិស័យសិល្បៈក៏ជាយានមួយយ៉ាងសំខាន់ ក្នុងការបង្កប់អត្ថន័យក្នុងការអប់រំ ។ យ៉ាងណាមិញ សិល្បៈខ្មែរដូចជាចម្រៀងចាប៉ី ចម្រៀងអាយ៉ៃ កុន ល្ខោន រហូតចម្រៀងសម័យទំនើបជាដើម អាចធ្វើជាឧបករណ៍សំរាប់ផ្សាយវប្បធម៌ សាសនា រហូតនយោបាយ ។ នៅសម័យពុទ្ធកាលមានដំណាលថា ពេលដែលព្រះពោធិសត្វព្រះឥសីសិទ្ធត្ថៈធ្វើទុក្ករកិរិយាយ៉ាងតឹងរ៉ឹង ដើម្បីរកធម៌ត្រាស់ដឹង ពេលនោះព្រះឥន្ទបានមកដេញពិណាច្រៀងជាប្រស្នាថា ពិណាកាលណារឹតខ្សែតឹងពេកអាចដាច់ខ្សែដេញពុំឮ រឹតធូរពេកក៏ដេញពុំឮ បើរឹតកុំឲ្យតឹងពេកកុំឲ្យធូរពេក ទើបដេញឮហើយពីរោះ ។ សម្លេងនោះបានឮដល់ព្រះពោធិសត្វ ព្រះអង្គបានយកជាគតិ ហើយលះបង់ការព្យាយាមដ៏តឹងរ៉ឹងផ្លូវខុសនេះ ព្យាយាមផ្លូវកណ្ដាលវិញ ទើបត្រាស់ដឹង ។ ប៉ុន្តែក្នុងសៀវភៅពន្លឺអាស៊ីទ្វីបវិញពុំនិយាយថា ព្រះឥន្ទដេញពិណាដូចក្នុងពុទ្ធប្រវត្តិទេ គឺនិយាយពីអ្នកភ្លេងធម្មតា ដើរកាត់តាមផ្លូវដែលព្រះពោធិសត្វធ្វើទុក្ករកិរិយា ហើយនារីម្នាក់ជាសមាជិកក្រុមភ្លេងនោះ ច្រៀងទៅកាន់អ្នករឹតពិណាមានន័យដូចពោលមកហើយ ។ ដូច្នេះបញ្ជាក់ថា ពិណាឬចាប៉ីអាចយកជាឧបករណ៍សំរាប់ដោះស្រាយប្រស្នាផ្សេងៗ កើតមានតាំងពីសម័យពុទ្ធកាល ។ ដូចគ្នានេះដែរ នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋខ្មែរបាននិយាយថា ស្មៀនឈិនចំរៀងអាយ៉ៃបានច្រៀងធម៌អាថ៌ មានច្រៀងរឿងពុទ្ធប្រវត្តិជាដើមកាលពីមុន ។ បច្ចុប្បន្ននេះទៀត ប្រាជ្ញឈួនអ្នកចំរៀងចាប៉ីច្រៀងរឿងពុទ្ធប្រវត្តិច្រៀងរឿងនគរកាយគតិលោកប្រៀបគតិធម៌ ច្រៀងច្បាប់ក្រមង៉ុយ ច្រៀងកេរ្តិ៍កាលជាដើម ។ ព្រះពុទ្ធបានហាមមិនឲ្យពុទ្ធបរិស័ទអ្នករក្សាសីល៨ស្ដាប់ចំរៀងក្នុងយប់មួយថ្ងៃមួយនោះ ដោយសារចម្រៀងទាំងនោះតែងច្រៀងទាក់ទងនឹងផ្លូវកាមគុណ រូប សម្លេង ក្លិន រសសម្ផស្ស ដែលនាំឲ្យចិត្តសៅហ្មង ដែលពុំមែនជាចម្រៀងអប់រំឲ្យចិត្តស្ងប់បរិសុទ្ធ ។ ចំណែកចម្រៀងបូរាណក្ដី ចម្រៀងសម័យក្ដី មានច្រើនប្រភេទ គឺចម្រៀងស្នេហាជាតិ ចម្រៀងប្រវត្តិសាស្ត្រ ចម្រៀងមនោសញ្ចេតនា ចម្រៀងបណ្ដុះឲ្យមានគុណធម៌ មានសីលគុណជាដើម ។ ប៉ុន្តែចម្រៀងខ្មែរសព្វថ្ងៃនេះច្រើននិពន្ធនិងច្រៀងមនោសញ្ចេតនារវាងបុរសនិងស្ត្រី ពុំសូវមានតែងនិពន្ធឲ្យមនុស្សមានគុណសម្បត្តិ ឆ្ពោះទៅរកការគោរពសិទ្ធិគ្នា ការមានសីលធម៌ឡើយ ។ មានកុនខ្មែរនិងចម្រៀងខ្មែរខ្លះ តែងនិពន្ធនិងច្រៀងមានលក្ខណៈប្រើអំពើហឹង្សា ការរំលោភសិទ្ធិគ្នា ការប្រើល្បិចបំផ្លាញគ្នាស្នេហាក្បត់ចិត្តគ្នាជាដើម ។ បើយុវជននិងយុវនារីខ្មែរ មើលនិងស្ដាប់អាចយកតម្រាប់តាម ព្រោះកុនល្ខោនចម្រៀង មានឥទ្ធិពលខ្លាំងណាស់ទៅលើយុវជនក្នុងបឋមវ័យ ដែលជាវ័យនៅទន់ខ្សោយខាងប្រាជ្ញាស្មារតី ។ មានអ្នកចម្រៀងស្នេហាសីលធម៌ម្នាក់ប្រាប់អាត្មាថា មានចម្រៀងមួយបទរបស់ស៊ិន-ស៊ីសាមុត ច្រៀងសម្លាប់ប្រពន្ធនៅពេលដែលប្រពន្ធមានចិត្តក្បត់ ។ គាត់មានប្រសាសន៍ថា ចម្រៀងបែបនេះមិនត្រូវយកមកច្រៀងទេ ព្រោះជាការបង្រៀនមនុស្សឲ្យក្បត់ចិត្តគ្នានិងឲ្យប្រើធម៌ហឹង្សា ។ គាត់សួរយោបល់អាត្មា អំពីចម្រៀងមួយបទទៀតរបស់ស៊ិនស៊ីសាមុត ដែលទាក់ទងនឹងពុទ្ធសាសនាថា អាំអើយស្រីអាំ ព្រះពុទ្ធលោកផ្ដាំ ឲ្យអាំគូនឹងបង តើពាក្យនេះជាពាក្យលើកតម្កើងព្រះពុទ្ធសាសនា ឬបង្អាប់ព្រះពុទ្ធសាសនា ? អាត្មាឆ្លើយថា ជាពាក្យបង្អាប់ព្រះពុទ្ធសាសនា ព្រោះព្រះពុទ្ធជាបុគ្គលបរិសុទ្ធផុតចាកគ្រឿងកង្វល់ទាំងអស់ មិនត្រូវលើកយកព្រះពុទ្ធជាបុគ្គលបរិសុទ្ធមកលាយឡំជាមួយមនុស្សបុថុជ្ជន ដែលប្រព្រឹត្តកាមគុណដូច្នេះឡើយ ។ ក្រសួងវប្បធម៌ត្រូវតែហាមមិនឲ្យចេញផ្សាយនូវចម្រៀងបែបនេះ ព្រោះជាពាក្យបន្ថោកតម្លៃព្រះពុទ្ធឲ្យចុះទាបទៅនៅស្មើនឹងមនុស្សធម្មតា ហើយជាការខុសការពិតផង ព្រោះពុំមែនព្រះពុទ្ធអង្គណាដែលផ្ដាំបុរសស្ត្រីណាឲ្យជួបគ្នាឡើយ នេះគ្រាន់តែជាការប្រឌិតរបស់អ្នកនិពន្ធប៉ុណ្ណោះ ។ មានអត្ថន័យបទមួយទៀតថា ពេលណាគេប្រាថ្នាអ្វីមិនបានដូចប្រាថ្នា ឬព្រាត់ប្រាស់គូស្នេហ៍របស់គេ គេបន្ទោសព្រះព្រហ្មលិខិត គឺបណ្ដាលមកពីព្រហ្មលិខិត ។ គាត់សួរអាត្មាថា តើការបន្ទោសព្រះព្រហ្មលិខិតនេះត្រឹមត្រូវទៅតាមអត្ថន័យព្រះពុទ្ធសាសនាឬទេ ? អាត្មាឆ្លើយថា ពុំត្រឹមត្រូវទៅតាមអត្ថន័យព្រះពុទ្ធសាសនាទេ ព្រោះព្រះពុទ្ធសំដែងថា សេចក្ដីសុខទុក្ខចំរើនវិនាសទាំងអស់ កើតមកអំពីអំពើរបស់ខ្លួន ពុំមែនកើតឡើងពីព្រះព្រហ្មលោកចារមកសរសេរមក ឬដាក់ក៏រឹតមកទេ ។ ដូច្នេះយើងអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវនាំគ្នានិយាយថា កម្មលិខិតទើបត្រឹមត្រូវ មិនត្រូវនិយាយថាព្រហ្មលិខិត ដែលជាព្រហ្មញ្ញសាសនានោះឡើយ ។ ចម្រៀងបែបនេះ មិនត្រូវឲ្យចេញផ្សាយទេ ព្រោះពុំត្រឹមត្រូវទៅតាមន័យរបស់ព្រះពុទ្ធសាសនា ។ មានតួអង្គកុននិងចម្រៀងខ្លះទៀតនិយាយនៅពេលដែលធ្វើបុណ្យកុសលណាមួយ ដូចជាដាក់បាត្រលោកហែកបិនជាដើមថា ធ្វើបុណ្យនេះដើម្បីទទួលផលជាតិក្រោយ ។ ពាក្យនេះត្រូវបានខ្លះប៉ុន្តែពុំត្រូវចំទេ ដោយបុណ្យកុសលដែលធ្វើបានផលតាំងពីជាតិនេះទៅ ព្រោះអ្នកធ្វើបុណ្យកុសលតែងមានចិត្តរីករាយជ្រះថ្លា មានគេស្រឡាញ់រាប់អានជាដើម ពុំមែនចាំតែជាតិក្រោយទេ ។ ដូច្នេះអ្នកដែលតែងកុនល្ខោននិងបទចំរៀង ដែលទាក់ទងនឹងព្រះពុទ្ធសាសនា គួរទៅពិគ្រោះសាកសួរអ្នកចេះដឹងព្រះពុទ្ធសាសនា កុំឲ្យភ្លាំងភ្លាត់បែបនេះ ។ គេអាចពោលថា ធ្វើបុណ្យដើម្បីសេចក្ដីសុខ គឺសុខក្នុងជាតិនេះនិងជាតិខាងមុខ ដោយសំអាងពុទ្ធភាសិតថា ការសន្សំនូវបុណ្យនាំមកនូវសេចក្ដីសុខ ។

### អំពីគុណភាពនៃទូរទស្សន៍ខ្មែរ CTN ដែលផ្សាយពីប្រទេសកម្ពុជា

ទូរទស្សន៍ខ្មែរ CTN ដែលផ្សាយពីទីក្រុងភ្នំពេញ ដែលសព្វថ្ងៃនេះគេអាចមើលឃើញនៅប្រទេសកាណាដា មានគុណភាពល្អមធ្យម ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋខ្មែរដែលនៅបរទេសចង់ឃើញចង់ឮដំណឹងពីមាតុប្រទេសរបស់ខ្លួនតាមរយៈទូរទស្សន៍ ទោះបីទូរទស្សន៍ខ្លះមានការលំអៀងទៅរកអ្នកកាន់អំណាចក៏ដោយ ។ ពេលនេះសូមបញ្ចេញទស្សនៈ តែទៅលើកម្មវិធីវប្បធម៌តែម៉្យាង ដើម្បីឲ្យស្របតាមប្រធានបទខាងដើមអំពីមុខនាទីសិល្បៈ ។ គួរឲ្យសរសើរអ្នកចាត់ចែងកម្មវិធីទូរទស្សន៍ CTN ដែលបានលើកយកសិល្បៈបូរាណ ដូចជាចំរៀងចាប៉ីចំរៀងអាយ៉ៃជាដើម ។ អ្នកស្ដាប់ពោលថា ពីដើមអ្នកចំរៀងអាយៃ

ដែលល្បីឈ្មោះ គឺស្មៀនឈិន ព្រោះក្រៅពីសម្លេងពីរោះក្រអួនតាមធម្មជាតិ គាត់ចេះប្រើពាក្យថ្លៃថ្នូរ ហើយលើកយកធម៌អាថ៌ព្រះពុទ្ធសាសនាមកច្រៀង ។ ជំនាន់ក្រោយមក គ្មានបុគ្គលណាស្នងគាត់ឡើយ ប៉ុន្តែគេសង្កេតឃើញថា ស្មៀនឈៀងច្រៀងតាមលំនាំស្មៀនឈិនដែរ ដូច្នេះគួរយកគាត់ជាគ្រូបង្ហាត់មនុស្សជំនាន់ក្រោយទៀត ។ ចំពោះអ្នកចំរៀងអាយ៉ៃនៅក្នុងទូរទស្សន៍ CNT សព្វថ្ងៃនេះ មានខ្លះច្រៀងគួរសម ប៉ុន្តែមានអ្នកចំរៀងខ្លះ ច្រើនអ្នកចំរៀងមានវ័យចាស់ ច្រៀងប្រើពាក្យអាស-អាភាស មានន័យទៅរកផ្លូវកាមគុណរវាងនុរសនិងស្ត្រី ។ គេឲ្យពេលច្រៀងតែកន្លះម៉ោង ច្រៀងប្រើពាក្យផ្តោះផ្តងឡែបខាយឥតមានប្រយោជន៍ជិតអស់ពេល ដល់ពេលសួរប្រស្នាតាមប្រធានបទ នៅសល់ពេលតិចបំផុត។ ដូច្នេះបើពុំកែឲ្យមានគុណភាព គឺលុបបំបាត់ពាក្យអាសអាភាសរបស់ចំរៀងអាយ៉ៃ តាមពាក្យរិះគន់របស់ទស្សនិកជនទេ គឺគេស្អប់អ្នកច្រៀង ប្រើពាក្យអាក្រក់អំពីរឿងភេទបុរសនិងស្ត្រី ខ្វះសេចក្តីថ្លៃថ្នូរ ខ្វះសីលធម៌ ។ ប្រទេសដែលមានការជឿនលឿនខាងសីលធម៌ គេមានការកំប្លែងដែរ ប៉ុន្តែការកំប្លែងរបស់គេខុសពីការកំប្លែងរបស់ខ្មែរ គឺគេកំប្លែងឲ្យសើចពីរឿងអ្វីមួយ ពុំទាក់ទងនឹងកាមគុណឡើយ ។ អ្នកកំប្លែងខ្មែរគប្បីតែសំរួលនូវការកំប្លែងរបស់ខ្លួន ឲ្យមានតម្លៃទៅលើការអប់រំវិញ កុំប្រើទម្លាប់ចាស់ដដែលៗ នៅតែជុំវិញភេទប្រុសនិងភេទស្រី ។ មួយទៀតគេសង្កេតឃើញថា អ្នកច្រៀងអាយ៉ៃក្មេងៗដូចជាច្រៀងមានសីលធម៌ជាអ្នកចម្រៀងចាស់ៗ ។ សុភាសិតបូរាណខ្មែរ ឬពាក្យព្រះពុទ្ធណាមួយមុននឹងយកមកច្រៀង គួរយកទៅពិគ្រោះជាមួយលោកអ្នកចេះដឹងឲ្យជួយបំភ្លឺបន្ថែម ដើម្បីកុំឲ្យអ្នកចំរៀងយល់ច្រឡំយកមកច្រៀងខុស ដូចមានកំហុសរួចមកហើយ ។

ចំពោះចម្រៀងចាប៉ី គេសរសើរលោកប្រាជ្ញឈ្មួន ព្រោះគាត់ច្រៀងចាប់ចុងជួនល្អ ប្រើពាក្យថ្លៃថ្នូរ សម្លេងធ្ងន់ពីរោះ ។ គាត់ច្រៀងចម្រៀងជាច្រើនទាក់ទងនឹងព្រះពុទ្ធសាសនា និងច្បាប់បូរាណ ទូន្មានកូនចៅផ្សេងៗ ។ គួរយកលោកប្រាជ្ញឈ្មួនធ្វើជាគ្រូបង្ហាត់ក្នុងសកលវិទ្យាល័យវិចិត្រសិល្បៈ ចំពោះវិជ្ជាចម្រៀងចាប៉ីនេះដល់និស្សិតជាការល្អណាស់ ។ ចំណែកគ្រូបង្រៀនចាប៉ីដទៃទៀត អ្នកស្តាប់និយាយថា ពុំសូវពីរោះ ច្រៀងច្រើនស្រែក ប្រើពាក្យពុំថ្លៃថ្នូរ កំប្លែងខុសការពិត ដូចកូនសិស្សលោកតាពូថៅដែជាដើម ។ ចំរៀងចាប៉ីគួរយកតាមដំណើរលោកតាប្រាជ្ញឈ្មួន ព្រោះដំណើរចំរៀងមានលើកដាក់ មានសម្លេងថ្លម ហើយប្រើពាក្យល្អទាន់សម័យ ទាន់ការលូតលាស់ខាងអក្សរសាស្ត្រ ដែលអាចឲ្យយុវជនសម័យថ្មីស្តាប់បានហើយគាត់ច្រើនច្រៀងចំពោះប្រធានបទ ដែលទាក់ទងទៅនឹងការអប់រំផង ។ អ្នកប្រាជ្ញខាងចិត្តវិជ្ជាផ្នែកការអប់រំមានយោ-បល់ថា បទចម្រៀងគេអាចនព្ចូលស្នេហាខ្លះ ប៉ុន្តែការបញ្ចូលនោះគ្រាន់តែជាមធ្យោបាយទាក់ទាញមនុស្សឲ្យស្តាប់ ដោយបង្កប់ន័យទូន្មានបែបណាមួយក្នុងបទចំរៀងនោះ មិនត្រូវបញ្ចូលស្នេហាខ្លាំងពេក រហូតធ្វើឲ្យអ្នកស្តាប់វង្វេងស្មារតី លុងលុះតាមបទចំរៀងនោះ ។ ប្រៀបដូចគេដាក់ជាតិស្ករ នៅជុំវិញគ្រាប់ថ្នាំដែលមានជាតិល្វីង ដើម្បីបញ្ឆោតក្មេងឲ្យលេប ដើម្បីឲ្យជារោគ ពុំមែនដាក់ស្ករហូតដល់ក្មេងលេបទៅនាំឲ្យឈឺពោះនោះទេ ។

ចំពោះព្រះសង្ឃដែលទេសនានៅក្នុងទូរទស្សន៍ CTN វិញ អ្នកស្តាប់សូមធ្វើសំណូមពរថា មុននឹងលើកយកធម៌ណាមួយមកទេសនា គួរយកធម៌នោះទៅពិគ្រោះជាមួយអ្នកចេះដឹងព្រះពុទ្ធសាសនា ឲ្យយល់ច្បាស់ជាមុនសិន ព្រោះកុំឲ្យច្រឡំសេចក្តីអធិប្បាយ ដូចបានទេសន៍កន្លងមកហើយ ។ មួយទៀត ពេលបញ្ចប់ទេសនា គួរជូនពរចំពោះប្រជាពលរដ្ឋខ្មែរ ដែលក្រីក្រលំបាក កំពុងរងទុក្ខវេទនា ឲ្យរួចអំពីភាពក្រីក្រ កុំឲ្យពរចំពោះតែអ្នកធំអ្នកមានអំណាច ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភនោះឡើយ ។๛